# សុន្ទរកថា

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ថ្លែងក្នុង

## ពិធីផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការ

## នូវ «ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច កម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣»

**តាមប្រព័ន្ធវីដេអូ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១, ម៉ោង ៩:៤៥ - ១០:០០**

- *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី;*
- *សមាជិក, សមាជិកា នៃអង្គពិធីជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សជាអនេក ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាអធិបតី ក្នុងពិធីផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការ នូវ «ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣» ។ ឯកសារដ៏មានសារសំខាន់នេះ គឺជាមូលដ្ឋានគ្រឹះ និង ជាផែនទីបង្ហាញផ្លូវ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ និង វិធានការសកម្មភាពជាក់លាក់របស់រាជរដ្ឋាភិបាល ក្នុងពេលចំពោះមុខ និង រយៈពេលមធ្យម, ម៉្យាង, សំដៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ឱ្យត្រឡប់ទៅរកកំណើនសក្តានុពលរបស់ខ្លួន, និងម៉្យាងទៀត, សំដៅពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និង បរិយាប័ន្ន នៅក្នុងរយៈពេលវែងផងដែរ ។

ក្នុងរយៈពេលប្រមាណ ២ ឆ្នាំ នៃវិបត្តិជំងឺកូវីដ-១៩ កន្លងទៅ, យើងទាំងអស់គ្នាអាចកត់សម្គាល់ឃើញយ៉ាងច្បាស់ នូវផលវិបាកអវិជ្ជមានដែលកើតចេញពីវិបត្តិនេះ មកលើស្ថានភាពសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ក្រៅពីការគំរាមកំហែង និង ការឆក់យកអាយុជីវិតប្រជាជន, វិបត្តិនេះបានលាតត្រដាងឡើង នូវចំណុចផុយស្រួយមួយចំនួន នៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ដែលងាយនឹងទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ ។ ជាក់ស្តែង, ការបន្ទុចបង្អាក់ទៅលើខ្សែច្រវាក់ផ្គត់ផ្គង់ និង ផលិតកម្ម ក៏ដូចជាការថមថយនូវតម្រូវការនៃការបញ្ជាទិញផលិតផលរបស់កម្ពុជា ក្រោយការដាក់ចេញនូវវិធានការសុខាភិបាល និង វិធានការរដ្ឋបាលនានា ពីសំណាក់បណ្តាប្រទេសនៅលើសកលលោក គឺជាសក្ខីភាពមួយដែលបង្ហាញថា ស្ថិរភាពរបស់វិស័យជាចន្ទល់នៃកំណើនសេដ្ឋកិច្ចកម្ពុជា មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនិន្នាការសេដ្ឋកិច្ចតំបន់ និង សកល ។ ការណ៍នេះមិនមែនមានន័យថា កម្ពុជាត្រូវកែសម្រួលនូវមូលដ្ឋានសេដ្ឋកិច្ចបើកចំហរបស់ខ្លួននោះទេ, តែផ្ទុយទៅវិញ, តថភាពនេះបានបង្ហាញឱ្យឃើញអំពីភាពចាំបាច់របស់កម្ពុជា ក្នុងការពង្រីកវិសាលភាពបណ្តាវិស័យជាចន្ទល់នៃកំណើនសេដ្ឋកិច្ច តាមរយៈការកែទម្រង់មុតស្រួច សំដៅបង្កើនពិពិធកម្មសេដ្ឋកិច្ច និង លើកកម្ពស់ភាពប្រកួតប្រជែង ក៏ដូចជាការពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព សម្រាប់រយៈពេលវែង នៅក្នុងបរិការណ៍ដែលសកលលោកដំណើរការប្រកបដោយអន្តរកម្មខ្ពស់ និង ពឹងផ្អែកគ្នាទៅវិញទៅមក កាន់តែខ្លាំង ។

ស្របពេលដែលជំងឺកូវីដ-១៩ បានលាតត្រដាងឡើង នូវចំណុចផុយស្រួយមួយចំនួនរបស់មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា, វិបត្តិនេះក៏បានបង្ហាញឱ្យឃើញនូវចំណុចខ្លាំងជាច្រើនដែរ ជាពិសេស ការសម្រេចចិត្តដ៏ត្រឹមត្រូវ និង ទាន់ពេលរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និង ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** នាពេលកន្លងទៅ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឧត្បាតនេះ និង ក្នុងការគ្រប់គ្រងរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និង លំនឹងនៃជីវភាពរបស់ប្រជាជន ។ ជាក់ស្តែង, វិស័យកសិកម្មរបស់កម្ពុជា នៅតែអាចរក្សាបាននូវលំនឹង និង កំណើនរឹងមាំ ហើយបានជួយស្រូបយកកម្លាំងពលកម្មមួយចំនួនដែលត្រូវបានផ្អាកការងារជាបណ្តោះអាសន្ន ពីវិស័យផ្សេងទៀត ។ ប្រការនេះបង្ហាញថា កសិកម្ម នៅតែជាវិស័យចន្ទល់ដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលត្រូវតែបន្តយកចិត្តទុកដាក់អភិវឌ្ឍ និង ធ្វើឧស្សាហូបនីយកម្មបន្ថែមទៀត ដើម្បីសម្រេចបាននូវសក្តានុពលកំណើននៃវិស័យនេះ ។ ជាមួយគ្នានេះដែរ, ការកសាងពង្រឹងសមត្ថភាពនៃវិស័យសុខាភិបាល

ដែលអាចឆ្លើយតបបានយ៉ាងរហ័សចំពោះវិបត្តិនេះ រួមមានជាអាទិ៍ ការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងដែលធ្វើឱ្យសម្រេចបាននូវភាពស៊ាំសហគមន៍ក្នុងកម្រិតដ៏ខ្ពស់ ក្នុងរយៈពេលដ៏ខ្លី និង ការដាក់ចេញអនុវត្ត យ៉ាងទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព នូវវិធានការសុខាភិបាល និង រដ្ឋបាលនានា ដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង ការពារអាយុជីវិតរបស់ប្រជាជន គឺជាតឹកតាងដែលឆ្លុះបញ្ចាំងអំពីភាពខ្លាំងរបស់រាជរដ្ឋាភិបាល និង ការដឹកនាំប្រកប-ដោយយុទ្ធសាស្ត្រត្រឹមត្រូវ, ច្បាស់លាស់, ប្រាកដនិយម និង ចក្ខុវិស័យដ៏វែងឆ្ងាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ ភាពខ្លាំងទាំងនេះ នឹងក្លាយជាកាតាលីករ និង កត្តាជំរុញដ៏សំខាន់ សម្រាប់ការស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឡើងវិញ ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក៏ដូចជាសម្រាប់ការកសាងអនាគតថ្មីនៃមាគ៌ាកំណើនសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព និង បរិយាប័ន្ន ដែលកាន់តែមានពិពិធកម្ម ព្រមទាំងមានភាពធន់ទៅនឹងវិបត្តិ និង មានភាពធន់ទៅនឹងផលរំខានពីកត្តាខាងក្រៅ នាអនាគត ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

រាជរដ្ឋាភិបាលដាក់ក្តីរំពឹងយ៉ាងមុតមាំថា បណ្តាវិធានការគោលនយោបាយដាក់លាក់នៅតាមសសរស្តម្ភទាំង ៣ ឬ 3Rs ដូចមានចែងក្នុងឯកសារ «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្ម-វិធី**» នេះ រួមមាន ៖ ការស្តារឡើងវិញ (Recovery), ការកែទម្រង់ (Reform), និង ការកសាងភាពធន់ (Resilience), នឹងមិនត្រឹមតែជួយជំរុញសេដ្ឋកិច្ចកម្ពុជា ឱ្យត្រឡប់មកស្ថិតលើមាគ៌ានៃកំណើនប្រកបដោយភាពរឹងមាំ, ចីរភាព និង បរិយាប័ន្នប៉ុណ្ណោះទេ, តែក៏នឹងជំរុញដល់ការ-កែប្រែនិម្មាបនកម្មសេដ្ឋកិច្ចកម្ពុជាថែមទៀតផងដែរ ពិសេសគឺការបង្កើនពិពិធកម្មសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីស្រវាចាប់យកទាន់ពេលនូវកាលានុវត្តភាពថ្មីៗដែលកំពុងលេចឡើង ស្របតាមនិន្នាការតំបន់ និង សកល ។ ទន្ទឹមនឹងការដាក់ចេញនូវកិច្ចការចម្បង ដែលមានឧបនិស្ស័យជាការកែទម្រង់ទ្រង់ទ្រាយធំ និង ជាប្រព័ន្ធ នៅក្នុងឯកសារ «**ក្រប-ខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ, រាជរដ្ឋាភិបាលក៏នឹងនៅតែយកចិត្តទុកដាក់ផងដែរ ដល់ការងារជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាការរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជន ដែលបាន និង កំពុងបន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញ និង ជំរុញអនុវត្ត នូវវិធានការអន្តរាគមន៍ជាក់លាក់ បន្តពីវិធានការអន្តរាគមន៍ទាំងឡាយដែលត្រូវបានដាក់ចេញចំនួន ១០ ជុំរួចមកហើយនោះ ។

ដាក់ស្តែង, ដើម្បីបន្តជួយសម្រាលបន្ទុកជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និង ងាយរងគ្រោះ, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវ **«កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩»** សម្រាប់រយៈពេល ៩ ខែទៀត, រហូតដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២០២២ ខាងមុខ ។ ជាមួយគ្នា, រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការ-អនុគ្រោះផ្នែកពន្ធ, ដូចដែលបានដាក់ចេញនៅក្នុងវិធានការអន្តរាគមន៍ទាំង ១០ ជុំកន្លងមក, សម្រាប់ឆមាសទី ១ នៃឆ្នាំ ២០២២ ដល់ប្រតិបត្តិករនៅក្នុងវិស័យទេសចរណ៍ និង វិស័យអាកាសចរណ៍ ដែលបានរងផលប៉ះពាល់ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ដើម្បីផ្តល់ការគាំទ្របន្ថែមដល់ធុរជនពាក់ព័ន្ធ ក្នុងការកែលម្អ និង ត្រៀមខ្លួនទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និង អន្តរជាតិ បន្ទាប់ពីកម្ពុជាត្រូវបានបើកពេញលេញឡើងវិញ ចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២១ មក ។ រាជរដ្ឋាភិបាលក៏បានត្រៀមថវិកាប្រមាណ ២៥០ លានដុល្លារអាមេរិក នៅឆ្នាំ ២០២២ សម្រាប់ការផ្តល់ឥណទានដោយត្រង់ពីធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank) និង ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) ដោយកំណត់អត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង, ក្នុងរង្វង់ពី ៥% ទៅ ៥,៥% ប៉ុណ្ណោះ, សម្រាប់វិស័យអាទិ-ភាពសំខាន់ៗ រួមមាន ៖ វិស័យកសិកម្ម, វិស័យអេកូទេសចរណ៍ និង វិស័យអាទិភាពមួយចំនួនទៀត ។

ជាមួយក្តីរំពឹងខ្ពស់, យើងក៏ទទួលស្គាល់ដែរថា ភាពជោគជ័យ និង ប្រសិទ្ធភាពនៃការ-ឈានទៅសម្រេចបានតាមគោលដៅដូចមានចែងក្នុង **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី»** នេះ នឹងក្លាយជាវិញ្ញាសាសាកល្បងថ្មីមួយទៀត ចំពោះសមត្ថភាពរបស់ក្រសួង-ស្ថាប័នពាក់-ព័ន្ធ នៅក្នុងកិច្ចសហការ និង ការរួមគ្នាដោះស្រាយបញ្ហាប្រឈមចំពោះមុខ, ពិសេសនៅក្នុងការអនុវត្តវិធានការគោលនយោបាយជាក់លាក់ ដែលមានចែងនៅក្នុងឯកសារនេះ ក្រោមការចូលរួមយ៉ាងសកម្មពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធ ជាពិសេស វិស័យឯកជន ។ ក្នុងស្មារតីជំរុញការអនុវត្ត **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣»** ឱ្យទទួលបានជោគជ័យជាផ្លែផ្កា តាមការគ្រោងទុក, បន្ថែមលើរបាយការណ៍សង្ខេប និង បទបង្ហាញលម្អិត របស់ **ឯកឧត្តម ផាន់ ផល្លា** និង **ឯកឧត្តម ហួត ពុំ** ខាងលើ, ខ្ញុំសូមអនុញ្ញាតចូលរួមចែករំលែកនូវមតិយោបល់មួយចំនួនថែមទៀត ដូចខាងក្រោម ៖

**ទី១.** រាជរដ្ឋាភិបាលចាត់ទុកការអនុវត្ត «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ ជាអាទិភាពដ៏ចម្បង នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ និងការកែទម្រង់ សម្រាប់រយៈពេលខ្លី និង មធ្យមខាងមុខ ។ វិធានការគោលនយោបាយ ដែលត្រូវបានដាក់ចេញនៅក្នុងផែនការសកម្មភាពនៃឯកសារនេះ មានលក្ខណៈមុតស្រួច និង ផ្តោតទៅលើលទ្ធផលជាចម្បង (Outcome-Driven) ដែលបម្រើឱ្យគោលបំណងនៃការជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញ និង ចាកចេញពីវិបត្តិជំងឺកូវីដ-១៩ ទៅបន្តដំណើរលើគន្លងនៃកំណើនថ្មីមួយ ដែលកាន់តែមានភាពខ្លាំងក្លា, ធន់, រឹងមាំ, ស្វាហាប់ និង ប្រកបដោយថាមពល ធៀបនឹងមុនពេលមានវិបត្តិ ។ ជាក់ស្តែង, ការកែទម្រង់ដែលត្រូវបានដាក់ចេញនៅក្នុង «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ, តួយ៉ាង ការកែលម្អបរិយាកាសធុរកិច្ច និង ការកែទម្រង់វិស័យដឹកជញ្ជូន និង ឡូជីស្ទីក ជាដើម, មិនត្រឹមតែអាចឆ្លើយតបបានទៅនឹងផលអវិជ្ជមានបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ ប៉ុណ្ណោះទេ, ប៉ុន្តែក៏នឹងដោះស្រាយបញ្ហាជាប្រព័ន្ធ ដែលបានកើតមានឡើង តាំងពីមុនមានវិបត្តិជំងឺកូវីដ-១៩ នោះ ផងដែរ ។ ហេតុនេះ, ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ឱ្យចូលរួមអនុវត្តផែនការសកម្មភាពទាំងឡាយនេះ ប្រកបដោយស្មារតីបុរេសកម្ម, ឆន្ទៈនយោបាយមុតស្រួច, ជាមួយនឹងភាពម្ចាស់ការ និង ការទទួលខុសត្រូវខ្ពស់ ។

**ទី២.** ការអនុវត្ត «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ នឹងទាមទារឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធបំផុត ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ។ ទោះបីជាផែនការសកម្មភាពនៃ «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ បានចង្អុលបង្ហាញភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធយ៉ាងច្បាស់លាស់ហើយក៏ដោយ, ការអនុវត្តជាក់ស្តែង នឹងតម្រូវឱ្យមានការចូលរួមពីភាគីដទៃទៀត រួមទាំងភាគីឯកជន, ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល នៅក្នុងការផ្តល់នូវការគាំទ្រ និងកិច្ចសម្របសម្រួលនានា, ជាពិសេស ការផ្តល់នូវអនុសាសន៍ និង ព័ត៌មានត្រឡប់ (Feedbacks) អំពីប្រសិទ្ធភាពនៃវិធានការ ព្រមទាំងបញ្ហាប្រឈមដែលនៅសេសសល់ ។ ក្នុងន័យនេះ, ខ្ញុំសង្ឃឹមថា កម្ពុជានឹងសម្រេចបាននូវសាមគ្គីភាព និង កិច្ចសហប្រតិបត្តិការពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីជានាឱ្យបេសកកម្មនៃការស្តារ និង ការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឡើងវិញនៅក្នុងបរិបទថ្មីនេះ អាចទទួលបានជោគជ័យតាមការរំពឹងទុក សម្រាប់ជាគុណប្រយោជន៍ដល់ប្រជាជន និង ប្រទេសជាតិទាំងមូល ។

**ទី៣.** ទោះបីជារាជរដ្ឋាភិបាលបានប្រកាសបញ្ចប់នូវ «**ព្រឹត្តការណ៍ ២០ កុម្ភៈ ឆ្នាំ ២០២១**» កាលពីថ្ងៃទី ២០ ខែ ធ្នូ នេះហើយក៏ដោយ, យើងទាំងអស់គ្នាមិនត្រូវមើលស្រាល

និង មានការធ្វេសប្រហែសចំពោះជំងឺកូវីដ-១៩ នេះឡើយ, ជាពិសេស ប្រភេទមេរោគបំប្លែងថ្មីៗ ដូចជា អូមីក្រុង (Omicron variant) ជាដើម ។ យើងទាំងអស់គ្នាត្រូវបន្តត្រៀមខ្លួនជាប់ជានិច្ច ចំពោះសេណារីយ៉ូអាក្រក់នៃការអូសបន្លាយយូរអង្វែងនៃវិបត្តិនៃជំងឺកូវីដ-១៩ នេះ តាមរយៈការរៀនរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ដោយប្រកាន់ខ្ជាប់ នូវវិធានការសុខាភិបាល ជាពិសេស វិធានការ «**៣-ការពារ និង ៣-កុំ**» ប្រកបដោយស្មារតីប្រុងប្រយ័ត្ន និង ទទួលខុសត្រូវខ្ពស់ ដើម្បីជានាការពារសុវត្ថិភាព និង សុខមាលភាពរបស់បុគ្គលនីមួយៗ ក៏ដូចជាការពារសុវត្ថិភាព និង សុខមាលភាពរបស់ក្រុមគ្រួសារ និង របស់សហគមន៍ ព្រមទាំងជានានូវនិរន្តរភាពនៃការបើកប្រទេស និង សកម្មភាពសង្គម-សេដ្ឋកិច្ច ពេញលេញឡើងវិញ មិនឱ្យមានការត្រឡប់ក្រោយ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសនេះសម្តែងនូវការវាយតម្លៃខ្ពស់ ចំពោះអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន និង តួអង្គពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មតាមចំណែករៀងៗខ្លួន ក្នុងការរៀបចំ និង ចងក្រងនូវ «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» ដ៏មានសារៈសំខាន់នេះ ។ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាល់ការគាំទ្រយ៉ាងសស្រាក់សស្រាំ តាមរយៈការផ្តល់អនុសាសន៍, ធាតុចូល និង មតិយោបល់នានា ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានធ្វើឱ្យ «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធី**» នេះ មានខ្លឹមសារគ្រប់ជ្រុងជ្រោយ និង ឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងនៃការស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិបទថ្មីនៃការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, សមាជិក និង សមាជិកាទាំងអស់ នៃអង្គពិធីទាំងមូល មានសុខភាពល្អ, ចៀសផុតពីជំងឺកូវីដ-១៩ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវ «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣**» ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**